ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤៩
ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខៈ ៥៦៩
ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌលេខ ០៧ “ឆ”
ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤

# ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការ
ជាសាធារណៈ នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤
ដោយមានសមាសភាព៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី[redacted] ជា ចៅក្រមប្រឹក្សា
លោកស្រី[redacted] ជា ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ជា ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ឆ្នាំង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ជា ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

ដើម្បីជំនុំជម្រះទៅលើសំណុំរឿងព្រហ្មទណ្ឌលេខ៖១៤៩ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted]ខេង ភេទប្រុស អាយុ ៤០ឆ្នាំ កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨២ ជនជាតិខ្មែរ មុខរបរ គ្រូបង្រៀន ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ឃុំ[redacted]ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ[redacted] “ស” ម្តាយឈ្មោះ[redacted]“រ” ប្រពន្ធឈ្មោះ[redacted] មានកូនចំនួន ០១ នាក់ ទោសពីមុន (គ្មាន )។ ឃុំខ្លួន៖ ២៣.០៣.២០២៣

ជាប់ចោទពីបទៈ **ផលិត ចែកចាយរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ** ប្រព្រឹត្តនៅខេត្តកំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅសាលាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេចនរោត្តមសីហមុនី ស្ថិតក្នុងភូមិ[redacted] ឃុំ[redacted] ស្រុក[redacted] ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

**មានលោកមេធាវី[redacted]លី និងលោកមេធាវី[redacted]សោង ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]ខេង ។**

## ដើមបណ្តឹងរដ្ឋប្បវេណី

១-ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ៤៤ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្ត [redacted] ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្តកំពង់ឆ្នាំង។

២-ឈ្មោះ [redacted] មនះ ភេទស្រី អាយុ៤៣ ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្តកំពង់ឆ្នាំង។

មានលោកស្រីមេធាវី [redacted] រួចលី ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

## ជនរងគ្រោះ

-ឈ្មោះ [redacted] ហ្សួរ ភេទស្រី អាយុ១៥ ឆ្នាំ ជនជាតិខ្មែរ មុខរបរ សិស្ស ទីកន្លែងកំណើតនៅភូមិស្រែប្រិយ ឃុំ [redacted] ស្រុក [redacted] ខេត្ត [redacted] ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្តកំពង់ឆ្នាំង។

មានលោកមេធាវី [redacted] សម័យ និងលោកមេធាវី [redacted] ឡាយ ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះឈ្មោះ [redacted] ហ្សួរ។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០២២ ស្ថិតនៅខេត្តកំពង់ឆ្នាំង មានជនសង្ស័យឈ្មោះ [redacted] ខេង ភេទប្រុស អាយុ៤០ឆ្នាំ បានប្រើប្រាស់ទូរស័ព្ទដៃចំនួន០១ គ្រឿង ម៉ាក Iphone 13 Pro Max ពណ៌ Sierra Blue ធ្វើសកម្មភាពថតរូបភាពអាក្រាតកាយចំនួន០២ រូបភាព និងវីដេអូសកម្មភាពនៃការរួមភេទចំនួន០២ ឃ្លីប ដែលឃ្លីបទី១ មានរយៈ ពេល ១ នាទី ៣៦ វិនាទី និងឃ្លីបទី២ មានរយៈពេល ១ នាទី០៥ វិនាទី របស់ជនរងគ្រោះឈ្មោះ [redacted] ហ្សួរ ភេទស្រី អាយុ ១៥ឆ្នាំ ហើយជនសង្ស័យឈ្មោះ [redacted] ខេង បានយករូបភាព និងវីដេអូអាសអាភាសទាំងនោះទៅចែកចាយឱ្យអ្នកដទៃ រហូតមានការចែកចាយបន្តដោយជនមិនស្គាល់អត្តសញ្ញាណនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣ ក្នុងពិធីជប់លៀងអាពាហ៍ពិពាហ៍របស់គ្រួសារអង់គ្លេសឈ្មោះ [redacted] លី ស្ថិតនៅភូមិ [redacted] ខេត្តកំពង់ឆ្នាំង។ បន្ទាប់មកនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ នៅពេលដែលជនរងគ្រោះឈ្មោះ [redacted] ហ្សួរ និងមិត្តភក្តិចំនួន ០៥ នាក់ទៀតទៅជួបជនសង្ស័យឈ្មោះ [redacted] ខេង នៅក្នុងសាលរដ្ឋបាលនៃសាលាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេចនរោត្តមសីហមុនី ស្ថិតក្នុងភូមិ [redacted] ខេត្តកំពង់ឆ្នាំង ជនសង្ស័យបានចាប់បោកជនរងគ្រោះឈ្មោះ [redacted] ហ្សួរ ផ្ទប់ទៅនឹងតុហើយរួលលត់ជង្គង់បណ្តាលឱ្យរងរបួសជាំដើមដៃខាងឆ្វេង ប្រវែង ៦០ មីលីម៉ែត្រ គុណនឹង ៤០ មីលីម៉ែត្រ និងជាំជង្គង់ខាងឆ្វេង។

**បានឃើញ៖** របាយការណ៍សំយោគលេខ ០៨ របក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង។

**បានឃើញ៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១០៨ ដ.ស.ស/២៣ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

បានឃើញ៖ ដីកាសន្និដ្ឋានស្ថាពរលេខ ១៧៨៦ ដ.ស.ព/២៣ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

បានឃើញ៖ ដីកាដំណោះស្រាយលេខ ៣៨៤/២៣ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ឆ្នាំង។

បានឃើញ៖ ដីកាចាត់តាំងចៅក្រមក្រុមប្រឹក្សាជំនុំជម្រះលេខ ៦១៥/២៣ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted]នេង បានឆ្លើយនាពេលសវនាការថា៖ ខ្លួនស្គាល់ឈ្មោះ [redacted]ហ្វូរ តាំងពីខែមីនា ឆ្នាំ២០២២ តាមរយៈសិស្សរៀនចំណេះដឹងទូទៅ និងរៀនភាសាអង់គ្លេសឯកជនថ្នាក់ក្រៅម៉ោងជាមួយខ្លួន។ កាលពីដំបូងគាត់ និងខ្លួនជាសិស្ស និងជាគ្រូធម្មតាទេ ហើយគាត់ឆាតតាមតេឡេក្រាមពាក់ព័ន្ធរឿងមេរៀន បានរយៈពេល ០៣ខែ ក៏មានភាពស្និតស្នាលជាមួយគ្នា ដោយឆាតមានលក្ខណៈស៊ីជម្រៅជាមួយគ្នា សួរនាំសុខទុក្ខគ្នាទៅវិញទៅមក។ ជាទូទៅនៅម៉ោង ០៥ ល្ងាច ខ្លួនទំនេររយៈពេល ១៥ នាទី ឈ្មោះ [redacted]ហ្វូរ តែងតែទៅទិញអីយកមកហូបជាមួយមិត្តភក្តិរបស់គាត់ និងគាប់ជួនពេលនោះដែរ ខ្លួនក៏បានផ្ញើគាត់ឱ្យជួយទិញអីហូបដែរ គាត់តែងតែបានផ្ញើសារសួរសុខទុក្ខ និងសួរមេរៀនមកខ្លួនរាល់ល្ងាច។ បន្ទាប់មក បានយល់ចិត្តគ្នាស្រឡាញ់គ្នាទៅវិញទៅមក។ នៅមុនថ្ងៃបុណ្យភ្ជុំបិណ្ឌមួយថ្ងៃ គាត់បានផ្ញើសារមកថានៅថ្ងៃនេះគាត់ចង់ដើរលេងទៅញ៉ាំអី ខ្លួនឆ្លើយថាអូខេ ទៅម៉ោងប៉ុន្មាន? គាត់ថាទៅម៉ោង ០៣ និង ៣០ នាទីរសៀល គាត់ថាឱ្យខ្លួនទៅយកគាត់នៅតាមផ្លូវចូលផ្ទះមិត្តភក្តិរបស់គាត់នៅភូមិច្រកមៀត ពេលគាត់ឡើងឡានរួចខ្លួនសួរគាត់ថា "ចង់ទៅណា?" គាត់ថា "ចង់ទៅណាក៏បាន" ខ្លួនសម្រេចចិត្តជិះគាត់ទៅខុឌុង្គទៅញ៉ាំអីនៅទីនោះ ហើយគាត់បានខ្ចប់នំភីហ្សាមួយយកមកហូបនៅក្នុងឡាន និងធ្វើដំណើរទៅមុខ និងបានឯកភាពគ្នាទៅញ៉ាំនៅក្នុងបន្ទប់ផ្ទះសំណាក់នៅស្រុកខុឌុង្គ ពេលទៅដល់ផ្ទះសំណាក់ហូបនិងរួចក៏មានអារម្មណ៍ល្អជាមួយគ្នា ហើយក៏ព្រមព្រៀងគ្នារួមភេទជាមួយគ្នានៅទីនោះ។ នៅវេលាម៉ោង ០៦ នាទីល្ងាចក៏ត្រឡប់មកវិញ ហើយជូនគាត់ទៅយកម៉ូតូវិញ ហើយគាត់ជិះម៉ូតូទៅផ្ទះបែកគ្នាពេលនោះ។ ក្រោយមកទៀត គាត់តែងតែឱ្យខ្លួនទៅយកគាត់ក្នុងមួយអាទិត្យមួយដងទៅពីរដង។ ពេលគេងនៅផ្ទះសំណាក់ជាមួយគ្នា បានព្រមព្រៀងគ្នាថតរូបសិចបាន២ដង និងថតជាវីដេអូបានចំនួន ០៣ ដង។ ខ្លួនធ្លាប់សួរគាត់ចង់រៀនបើកឡានអត់ គាត់ឆ្លើយថាចង់រៀនបើកឡាន ពេលបង្រៀនបើកឡានលើកទី១ មានមិត្តភក្តិរបស់គាត់ឈ្មោះ លីម៉ា ទៅជាមួយដែរ។ ពេលខ្លួន និងឈ្មោះ [redacted]ហ្វូរ ទៅដើរលេង បានទិញភីហ្សា និងកូកាកូឡា ហើយយកទៅហូបនៅផ្ទះសំណាក់ជាមួយគ្នា។ ពេលហូបរួច ក៏បានព្រៀមព្រៀងគ្នារួមភេទ ព្រមទាំងបានថតរូបភាពជាសិចកែ និងជាវីដេអូផងដែរ ដោយមិនបានបង្ខិតបង្ខំនោះទេ។ ចំពោះទូរស័ព្ទម៉ាក IPHONE 11 ខ្លួនដូរឱ្យគាត់។ ខ្លួនយកទូរស័ព្ទម៉ាក IPHONE 13 PRO MAX ថតរូបភាពអាក្រាតកាយទាំងអស់ ដោយខ្លួនកាន់ដោយផ្ទាល់ដៃ។ ចំណែកឯ ចិញ្ចៀនមានអក្សរ ហ ជាចិញ្ចៀនរបស់ខ្លួន។ ខ្លួនជាអ្នករស់នៅកំពង់ត្រឡាច បានប្រហែល ១០ ឆ្នាំ មានមិត្តភក្តិជាគ្រូបង្រៀន និងបានទៅញ៉ាំការគ្រូបង្រៀនដូចគ្នា។ រាល់ពេលថតរូប ជនរងគ្រោះដឹង ដោយព្រមព្រៀងគ្នា ហើយខ្លួនមិនធ្លាប់ផ្ញើឱ្យអ្នកផ្សេងនោះទេ ហើយរូបភាពមួយ

ចំនួន ឈ្មោះ[redacted]ហ្សួរ ជាអ្នកកាន់ថតខ្លួនឯង។ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ០៣ និង ០០ រសៀល ខ្លួនបានអង្គុយលើតុស្រាប់តែរមាស់ មិនដឹងរមាស់អី មើលទៅលើតុឃើញសុទ្ធតែខ្មែរ ខ្លួនសួររកមុខអ្នកដាក់ខ្មែរមិនឃើញទេ ខ្លួនក៏ហៅសិស្សមួយថ្នាក់ទៅទីចាត់ការចែកក្រដាសពិន្ទុប្រចាំខែ រួចខ្លួនសួរសិស្សថា តើអ្នកណាខ្លះទៅលេងតុលោកគ្រូ ពេលនោះប្រធានថ្នាក់បានកត់ឈ្មោះ ០៨ នាក់ ក្នុងនោះមានឈ្មោះ[redacted]ហ្សួរ ម្នាក់ដែរ ពេលនោះខ្លួនទុកតែសិស្សចំនួន ០៨នាក់នោះទេ ក្រៅពីនេះគាត់ទៅផ្ទះចុះ ហើយខ្លួនហៅសិស្សប្រហែលជា ០៧-០៨ នាក់ នោះទៅបន្ទប់របស់ខ្លួនចង់សួរឱ្យដឹងថាតើអ្នកណាមួយជាអ្នកដាក់ខ្មែរនោះ តែដោយឈ្មោះ[redacted]ហ្សួរ គាត់ភ្លេចទូរស័ព្ទដៃគាត់នៅតុរៀន មិត្តភក្តិគាត់យកមកឱ្យខ្លួន ខ្លួនក៏យកទុកតែដោយឈ្មោះ[redacted]ហ្សួរ គាត់ដឹងថាទូរស័ព្ទដៃគាត់នៅនឹងខ្លួននោះ គាត់ក៏ទទួចយកទូរស័ព្ទរបស់គាត់វិញ ខ្លួនមិនទាន់ឱ្យទេគាត់ក៏ឆក់យកការបូបឆក់មិនបាន គាត់ឃើញទូរស័ព្ទដៃរបស់ខ្លួនទុកលើតុ គាត់ក៏ឆក់យកទូរស័ព្ទដៃរបស់ខ្លួន ពេលនោះខ្លួនក៏ក្រវៀសដៃ និងចាប់កំភួនដៃឆ្វេងគាត់ជាប់ គាត់ក៏រើ ហើយក៏បានទទ់ជង្គង់លុតទៅលើឥដ្ឋការ៉ូ។ ចំពោះរឿងហិង្សាលើឈ្មោះ [redacted]ហ្សួរ ខ្លួនបានចេញថ្លៃព្យាបាលអស់ចំនួន ១០០ (មួយរយ) ដុល្លាអាមេរិក និងចំនួន ៥០០០០ (ប្រាំម៉ឺន) រៀល ខ្លួនជាអ្នកចេញទាំងអស់ ហើយខ្លួនបានព្យាបាលឈ្មោះ[redacted]ហ្សួរ ដោយឪពុកម្តាយរបស់គាត់ព្រមទទួលយក។

-ជនរងគ្រោះឈ្មោះ[redacted]ហ្សួរ បានឆ្លើយនាពេលសវនាការថា៖ កាលពីអំឡុងខែមេសា ឆ្នាំ២០២២ ខ្លួនរៀនថ្នាក់ទី៩ ជាឆ្នាំប្រឡង ខ្លួនបានរៀនគួរភាសាអង់គ្លេសជាមួយលោកគ្រូឈ្មោះ[redacted]ខេង ពីម៉ោង ០៥ ល្ងាចដល់ម៉ោង ០៧ ព្រលប់ជាមួយគាត់ធម្មតា។ នៅមុនចូលរៀនគួរភាសាអង់គ្លេស គាត់តែងតែជជែកលេងរឿងជាច្រើន ខ្លួនបានឆាតក្នុងក្រុបធម្មតា ទំនាក់ទំនងគ្នាធម្មតា មិនស្និតស្នាលនោះទេ។ មុនភ្ជុំ គាត់មកជជែកពីរឿងឡាន ហើយសួរខ្លួនថា "ចេះបើកឡានដែរឬទេ?" ពេលនោះខ្លួនឆ្លើយថា "មិនចេះទេ" គាត់ថាចាំគាត់ជួយបង្រៀនខ្លួន ពេលនោះក៏មានសិស្សដទៃទៀតនៅទីនោះដែរ។ ក្រោយមកពេលខ្លួនប្រឡងឌីប្លូមរួចហើយ ក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ គាត់ក៏បបួលខ្លួនទៅបើកឡានជាមួយគាត់ នៅវេលាម៉ោងប្រហែល ០៣-០៤ រសៀល ខ្លួនក៏ទៅបើកឡានជាមួយគាត់នៅម្តុំផ្សារគ្រាចនៅដីឡូតិ៍ទំនេរមួយកន្លែងដោយទៅជាមួយមិត្តភក្តិឈ្មោះ លីម៉ា ផងដែរ។ ខ្លួនទៅជាមួយឈ្មោះ[redacted] លីម៉ា បានចំនួន ០២ដង និងទៅម្នាក់ឯងបានចំនួន ០១ដង។ គាត់បានបបួលខ្លួនទៅបើកឡាន ពេលជិះទៅដល់ផ្សារគ្រាច គាត់ថាឱ្យឈប់ឡានទិញអីញ៉ាំសិន ពេលនោះគាត់ទិញកូកាកូឡា ចំនួន០២កែវជ័រឱ្យខ្លួនមួយកំប៉ុងគាត់យកមួយកំប៉ុង ពេលហូបរួចគាត់បានប្រាប់ពីរបៀបបើកបរឡានមួយសន្ទុះ ខ្លួនក៏មានអារម្មណ៍មិនស្រួលខ្លួនឈឺក្បាល ហត់ បេះដូងដើរញាប់ ញ័រដៃ ញ័រជើង និងចង់សំងំដេក ហើយសុំគាត់ប្តូរកៅអីទៅកៅអីក្បែរអ្នកបើកវិញ ហើយដឹងថាឡានបើកទៅមុខតែមិនដឹងថាទៅណា ហើយខ្លួនក៏ដេកលក់ទៅ។ នៅវេលាម៉ោង ០៦ ជិត ០៧ យប់ ខ្លួនដឹង ខ្លួននៅក្នុងឡានគាត់ដាស់ឱ្យភ្ញាក់ទៅផ្ទះនៅម្តុំមុខផ្ទះឈ្មោះ[redacted]ម៉ា ពេលដឹងខ្លួន ខ្លួនមានអារម្មណ៍ឈឺក្បាល ឈឺខ្លួន ឈឺដើមទ្រូង និងឈឺប្រដាប់ភេទ។ លុះនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ០៨ យប់ គាត់បានផ្ញើរូបវីដេអូអាក្រាតកាយពេលគាត់កំពុងរំលោភខ្លួនមកឱ្យខ្លួនតាមតេឡេក្រាម ភ្លាមនោះគាត់ក៏លុបចេញវិញ ខ្លួនមិនបានឱ្យគាត់ផ្ញើវីដេអូមកទេ។ ចំពោះរឿងភ្លេចទូរស័ព្ទនោះ ខ្លួនបានសុំគាត់ឱ្យប្រគល់ទូរស័ព្ទវិញ ប៉ុន្តែគាត់មិនឱ្យ ទើបប្រតាយប្រតប់គ្នា។ គាត់ផ្ញើវីដេអូ និងរូបភាពមកខ្លួនហើយលុបវិញ ខ្លួនមិនដឹងថាគាត់បាញ់ឱ្យអ្នកណានោះទេ។រូបភាពថតឃើញខ្លួនញញឹម គឺគាត់បង្ខំឱ្យញញឹម។

ខ្លួនបានទៅជាមួយគាត់សរុបចំនួន ០៤ ដង ទៅលើកទី៣ បានថតរូបភាព និងថតជាវីដេអូ ដោយមិនបានប្រើហិង្សានោះទេ គាត់កាន់ទូរស័ព្ទដៃថតរូបខ្លះ ខ្លួនកាន់ទូរស័ព្ទដៃថតរូបខ្លះ។ ចំពោះវីដេអូរួមភេទលើកទី២ ដែលមានខ្លួនខាំមាត់ ហើយមានបញ្ចេញសម្លេងផងនោះ គឺដោយសារខ្លួនមានអារម្មណ៍ ហើយទប់អត់បាន។ គាត់ធ្លាប់បានយកវីដេអូមកគំរាម ហើយខ្លួនបានគេចវេស តែគាត់នៅដើរតាមខ្លួនជាប់ និងដាក់សម្ពាធមកលើខ្លួន។ ក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ ពេលខ្លួនចេញពីរៀនទៅយកម៉ូតូកន្លែងផ្ញើលោកគ្រូបានស្កាត់ជួបខ្លួន ហើយនិយាយថា "ទៅជាមួយគាត់ទៀតដែរឬអត់?" ខ្លួនឆ្លើយថា "មិនទៅទេ" គាត់ថា "មានវីដេអូក្នុងដៃឥឡូវចង់យ៉ាងមិច?" ខ្លួនក៏យកម៉ូតូជិះទៅផ្ទះ ដោយសារភ័យខ្លាចគាត់បង្ហោះរូបអាក្រាតកាយរបស់ខ្លួន និងដឹងដល់ម៉ាក់ប៉ា លុះដល់ម៉ោងជិត ០៣ រសៀល ខ្លួនបានទៅជាមួយគាត់ដោយទុកម៉ូតូនៅផ្ទះឈ្មោះ លីម៉ា គាត់ក៏បានបើកឡានទៅហួសផ្សារត្រាចទៅផ្ទះសំណាក់។ ពេលទៅរៀនរាល់ថ្ងៃ ទើបតែកើតរឿងថ្មីៗ គេរើសអើងខ្លួន ហើយមានរឿងអីខ្លួនប្រាប់ឈ្មោះ លីម៉ា មុនគេ។ លុះនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ គាត់បានចាប់យកទូរស័ព្ទរបស់ខ្លួនដោយចោទថា ខ្លួនលេងទូរស័ព្ទ នៅម៉ោងរៀន ពេលនោះខ្លួនបានទៅយកទូរស័ព្ទក្នុងបន្ទប់គាត់ធ្វើការជាមួយមិត្តភក្តិ ០៧ ទៅ ០៨ នាក់ ពេលនោះ គាត់ទាញដៃខ្លួនបោកទៅនឹងតុ និងឥដ្ឋការ៉ូបណ្ដាលឱ្យជាំដើមដៃ រលាត់កែងដៃ និងក្បាលជង្គង់តែគាត់នៅតែមិនឱ្យទូរស័ព្ទខ្លួនទេ ស្អែកឡើងខ្លួនទៅយកទូរស័ព្ទទៀតគាត់នៅតែមិនឱ្យ លុះដល់ម៉ាក់ប៉ាទៅយកទើបគាត់ឱ្យ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ហុង បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ មានគេទូរស័ព្ទមកប្រាប់ថា គ្រូឈ្មោះ [redacted]ខេង បានវាយកូនរបស់ខ្លួនឈ្មោះ [redacted]ហួរ បណ្ដាលឱ្យរបួសដើមដៃ និងស្នាមជាំខ្មៅក្បាលជង្គង់ ពេលទៅដល់កូនសិស្សប្រាប់ថាលោកគ្រូ [redacted]ខេង ជាអ្នកវាយ។ ហើយពួកខ្ញុំ និងគ្រូឈ្មោះ [redacted]ខេង បាននាំគ្នាទៅសាលាស្រុក ដើម្បីដោះស្រាយគ្នា ហើយក៏បានធ្វើកិច្ចសន្យាដោយសុំឱ្យគាត់ឈប់ប្រើអំពើចឹងទៀត។ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ ពេលព្រឹក ប្អូនថ្លៃឈ្មោះ[redacted]ម៉ាស់ បានឆាតប្រាប់ខ្លួនថា "បងអើយ ខ្ញុំទៅស៊ីការ យប់មិញនោះ ខ្ញុំឮគេជជែកគ្នាថាកូនរបស់បងបានទៅដេកជាមួយលោកគ្រូបង្រៀនម្នាក់បានចំនួន ០៣ ទៅ ០៤ ដង" ពេលនោះខ្លួនក៏ហៅកូនខ្លួនមកសួរ កូនឆ្លើយថា "ចាសប៉ាពិតមែន ព្រោះគេដាក់ថ្នាំខ្ញុំ ចាប់បង្ខំចាប់រំលោភ" ខ្លួនក៏បបួលប្រពន្ធទៅប្តឹងនៅប៉ូលីសស្រុកកំពង់ត្រឡាច។ ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ និងទាមទារសំណងជម្ងឺចិត្តចំនួន ២០០,០០០,០០០ (ពីររយលាន) រៀល។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]មនះ បានឆ្លើយនាពេលសវនាការថា៖ ខ្លួនត្រូវជាម្ដាយរបស់ជនរងគ្រោះ ខ្លួនប្តឹងឈ្មោះ [redacted]ខេង រឿងបែកធ្លាយវីដេអូរួមភេទកូនរបស់ខ្លួន ខ្លួនដឹងរឿងនេះដោយសារឈ្មោះ [redacted]ម៉ាស់ និយាយប្រាប់ខ្លួន គឺដឹងរឿងនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣។

-សាក្សីឈ្មោះ[redacted] សុជា បានឆ្លើយនាពេលសវនាការថា៖ ទំនាក់ទំនងរវាងគ្រូឈ្មោះ [redacted]ខេង និងឈ្មោះ [redacted]ហួរ ជាទំនាក់ទំនងធម្មតាដូចគ្រូ និងសិស្ស។ ទូរស័ព្ទរបស់ឈ្មោះ[redacted]ហួរ ភ្លេចនៅក្នុងថតតុក៏បានយកទូរស័ព្ទនោះទៅឱ្យឈ្មោះ [redacted]ហួរ នៅតាមផ្លូវទៅទីចាត់ការ ឈ្មោះ[redacted]ហួរ ដើរចេញពីទ្វារបន្ទប់រៀនក៏លោកគ្រូឈ្មោះ[redacted]ខេង ស្ទាក់យកទូរស័ព្ទនោះពីមិត្តភក្តិរបស់ឈ្មោះ[redacted]ហួរ ពេលនោះឈ្មោះ[redacted]ហួរ មិនបានដឹងទេ តែមិត្តភក្តិរបស់ឈ្មោះ[redacted]ហួរ បាននិយាយប្រាប់ឈ្មោះ[redacted]ហួរ ឱ្យដឹង ហើយឈ្មោះ[redacted]ហួរ ក៏

បានដើរទៅសុំទូរស័ព្ទពីលោកគ្រូវិញ តែលោកគ្រូមិនឱ្យទេ ហើយឈ្មោះ [redacted]ហួរ បានសំពះសុំជាច្រើនដងលោកគ្រូ នៅតែមិនឱ្យ ពេលនោះលោកគ្រូចាប់ដើមដៃរបស់ឈ្មោះ [redacted]ហួរ ជាប់ក្រវាត់បុកទៅតុ និងរួលអុកគូទទៅលើការ៉ូ។

-សាក្សីឈ្មោះ [redacted]ម៉ាស់ បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ០៨ យប់ជាង នៅកន្លែងរោងការរបស់លោកគ្រូ [redacted]លី ខ្លួនលឺគេនិយាយគ្នាថា លោកគ្រូឈ្មោះ [redacted]ខេង បានដេកជាមួយឈ្មោះ [redacted]ហួរ ហើយមានវីដេអូរទៀត គេមិនបាននិយាយចំត្រកូលទេ និយាយតែឈ្មោះ។ លុះនៅព្រឹកថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ ខ្លួនក៏ឆាតទៅសួរបងស្រីសាច់ថ្លៃពីរឿងដែលគេនិយាយនោះ។ ខ្លួនមិនបានឃើញរូបភាពនោះទេ ហើយមិនស្គាល់ និងមិនចំណាំអ្នកដែលនិយាយគ្នានោះទេ អ្នកនិយាយនៅតុក្រោយតុរបស់ខ្លួន ស្តាប់មិនសូវច្បាស់ទេ ហើយក៏មិនដឹងថាអ្នកណាជាអ្នកនិយាយដែរ។

**សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ**

-លោកស្រី [redacted]លី ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបាន ស្តាប់ការសួរដេញដោលនាពេលសវនាការ និងពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿងឃើញថា រឿងនេះពាក់ព័ន្ធមាន ៣ បទល្មើស ទី១ រឿងហិង្សា ដោយជនជាប់ចោទបានសារភាព និងទទួលស្គាល់រួចហើយថាខ្លួនពិតជាបានប្រើអំពើហិង្សាទៅលើជនរងគ្រោះប្រាកដមែន។ ចំណុចទី២ បទល្មើសរំលោភ ខ្លួនស្នើសុំឱ្យតុលាការពិនិត្យឡើងវិញ ឃើញថា តាមការសួរដេញដោលរួចជនជាប់ចោទបានប្រព្រឹត្តបទល្មើសជាបន្តបន្ទាប់ ដោយបង្កើតជាបញ្ហាគំរាម ដើម្បីឱ្យកូនក្តីរបស់ខ្លួនធ្វើតាមបញ្ជា និងប្រើអំណាច ដើម្បីគំរាមគំហែងឱ្យកូនក្តីរបស់ខ្លួនទៅរួមភេទជាមួយជនជាប់ចោទជាបន្តបន្ទាប់ ដោយកូនក្តីរបស់ខ្លួនបានឆ្លើយបញ្ជាក់ថា ជនជាប់ចោទបានដាក់ថ្នាំ ហើយរំលោភដោយគ្មានការយល់ព្រមពីជនរងគ្រោះឡើយ។ សុំឱ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យអំពីករណីបទល្មើសរំលោភ។ មុនដំបូងរឿងហេតុកើតចេញពីការលួងលោមឱ្យជនរងគ្រោះ រៀនបើកឡាន កូនក្តីរបស់ខ្លួនជាអនីតិជន នៅក្មេងចង់ដឹងចង់លឺ បន្ទាប់មកដាក់ថ្នាំហើយឈានដល់ការចាប់រំលោភកូនក្តីរបស់ខ្លួន បន្ទាប់មកជនជាប់ចោទបានថតសកម្មភាពរួមភេទជាវីដេអូ និងរូបភាព ផ្ញើទៅជនរងគ្រោះ បន្ទាប់មកលុបវិញ កូនក្តីរបស់ខ្លួនមិនបានស្រលាញ់ជនជាប់ចោទឡើយ ដោយជនជាប់ចោទយកវីដេអូចាស់មកគំរាម ហើយជនជាប់ចោទបានគំរាមកំហែងទៅសាក្សីឈ្មោះ លីម៉ា បណ្តាលឱ្យឈ្មោះ លីម៉ា មិនហ៊ានទៅរៀន។ ប្រសិនបើ មិនបែកធ្លាយវីដេអូរនោះទេនឹងមានរឿងជាបន្តបន្ទាប់ ដែលដាក់សម្ពាធ ព្រមទាំងប្រើអំណាចរបស់ខ្លួនគៀបសង្កត់ដល់ជនរងគ្រោះ។ សុំឱ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ ពិចារណាលើករណីបទល្មើសរំលោភ ដើម្បីទទួលបានភាពស្អាតស្អំដល់កូនក្តីរបស់ខ្លួន។ ចំពោះករណីចែកចាយរូបភាពអាសអាភាស សុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទជាអតិបរមា ព្រោះជនជាប់ចោទជាគ្រូបង្រៀន កុំឱ្យមានគំរូអាក្រក់ដល់អ្នកក្រោយទៀត។

-លោក [redacted]សម័យ ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ និងពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿងឃើញថា ខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ ខ្លួនសូមបញ្ជាក់បន្ថែមលើសេចក្តីសន្និដ្ឋានរបស់លោកស្រីមេធាវី [redacted]លី ។ ជនជាប់ចោទ

បានឆ្លើយសារភាពរួចហើយ អំពីករណីហិង្សា និងថតរូបភាពវីដេអូអាក្រាតកាយ ប៉ុន្តែជនជាប់ចោទបានបដិសេធមិនបានចែកចាយនោះទេ តែបើពិនិត្យមើលចំណុចនេះ បើមិនចែកចាយវីដេអូ តើបានរូបភាពពីណាមក។ ជនជាប់ចោទបានឆ្លើយថា បានថតចំនួន ៣ វីដេអូ ថាតើមានវីដេអូថតប៉ុន្មាននាទី ។ តាមការបញ្ជាក់របស់តំណាងអយ្យការមាន២ វីដេអូ វីដេអូទី១មានរយៈពេល ១.០៦ នាទី វីដេអូទី២មានរយៈពេល ១.៣៦ នាទី នេះមានន័យថាមានភាពមិនប្រក្រតីដែលកូនក្តីរបស់ខ្លួនឆ្លើយថាក្រោយពីផឹកកូកាកូឡា ហើយបាត់បង់ស្មារតី បន្ទាប់មកផ្ញើវីដេអូមកឱ្យកូនក្តីខ្លួន។ តាមចម្លើយរបស់សាក្សីឈ្មោះ លីម៉ា បានឆ្លើយថា ក្រោយពេលដែលឈ្មោះ [redacted]ហួរ ត្រឡប់មកពីរៀនឡានវិញ ឃើញថាឈ្មោះ [redacted]ហួរ មានទឹកមុខស្លេកស្លាំង ឃើញថាពិតជាមានអង្គហេតុរំលោភប្រាកដមែន ប៉ុន្តែតំណាងអយ្យការមិនបានចោទប្រកាន់នោះឡើយ។ ជនជាប់ចោទបានយកវីដេអូចាស់ មកគំរាមជនរងគ្រោះដើម្បីបានរួមភេទជាបន្តបន្ទាប់ទៀតផង។

**សេចក្តីសន្និដ្ឋានស្តីពីសុំរបស់តំណាងអយ្យការ**

-តំណាងអយ្យការបានធ្វើសន្និដ្ឋាននាពេលសវនាការថា៖ ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿង ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ, ស្តាប់ចម្លើយរបស់ជនរងគ្រោះ, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ចម្លើយរបស់សាក្សី រួចមក តំណាងអយ្យការយល់ឃើញថា ពិតជាមានលក្ខណៈស៊ីសង្វាក់គ្នានឹងរបាយការណ៍សំយោគលេខ ០៨ របក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ដែលអាចបញ្ជាក់បានថាពិតជាមានអង្គហេតុនៃបទ ផលិត ចែកចាយរូបភាព អាសអាភាសនៃកុមារ និងបទ ហិង្សាដោយចេតនា ប្រាកដមែន។ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ[redacted]ហួរ និងចម្លើយរបស់ជនត្រូវចោទឈ្មោះ[redacted]ខេង ដែលបានឆ្លើយប្រហាក់ប្រហែលគ្នានៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះឃើញថា ជនរងគ្រោះ និងជនត្រូវចោទពិតជាបានធ្វើសកម្មភាពរួមរ័ក្សគ្នា ហើយជនត្រូវចោទបានយកទូរស័ព្ទដៃមកថតសកម្មភាពរួមរ័ក្សនេះ និងថតរូបភាពអាក្រាតកាយរបស់ជនរងគ្រោះ រួចបានចែកចាយវីដេអូ និងរូបភាពទាំងនេះទៅអ្នកដទៃ ដោយមានសាក្សីឈ្មោះ [redacted]ម៉ាស់ បានបញ្ជាក់ថា ពេលខ្លួនទៅហូបការគេបានឮអ្នកអង្គុយតុជិតនិយាយគ្នាថា មានរូបភាពអាក្រាតកាយ និងវីដេអូរួមរ័ក្សរវាងជនត្រូវចោទឈ្មោះ [redacted]ខេង ជាមួយជនរងគ្រោះឈ្មោះ[redacted]ហួរ ដែលស៊ីសង្វាក់នឹងរបាយការណ៍កោសលវិច័យ និងភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿង ដែលការណ៍នេះអាចបញ្ជាក់បានថា ពិតជាបានផលិត និងចែកចាយរូបភាពអាសអាភាសរបស់ជនរងគ្រោះដែលជាអនីតិជន អាយុ១៥ ឆ្នាំ ដែលសន្ធិសញ្ញាអន្តជាតិ កំណត់ថាជាកុមារពិតប្រាកដមែន ហើយជនត្រូវចោទដែលជាអញ្ញត្រជនបានចែកចាយរូបភាពទាំងនោះបន្តទៅឱ្យអ្នកដទៃផ្សេងទៀត ត្រូវចៅក្រមស៊ើបសួរសម្រេចលើកលែងចោទប្រកាន់ដោយសារពុំអាចរកអត្តសញ្ញាណឃើញ។ ជនជាប់ចោទឈ្មោះ [redacted]ខេង បានឆ្លើយបដិសេធនៅក្នុងអង្គសវនាការថាខ្លួនពុំបានចែកចាយរូបភាព និងវីដេអូអាសអាភាសនោះទេ។ ការឆ្លើយនេះ គ្រាន់តែការឆ្លើយដោះសារយករួចខ្លួនប៉ុណ្ណោះ ព្រោះមិនមានភស្តុតាងណាដើម្បីឱ្យតុលាការជឿឡើយ។ តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ[redacted]ហួរ, ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ខេង និងចម្លើយរបស់សាក្សីឈ្មោះ [redacted]សុផា ដែលបានឆ្លើយប្រហាក់ប្រហែលគ្នាថា ជនជាប់ចោទឈ្មោះ [redacted]ខេង បានចាប់ដើមដៃរបស់ជនរងគ្រោះឈ្មោះ [redacted]ហួរ

ជាប់ក្រវាត់បុកទៅគុ និងកៅអីនៅដែលនៅក្បែរៗនោះ និងប្តូលអុកគូទទៅលើការ៉ូ នៅពេលដែលជនរងគ្រោះទៅសុំទូរស័ព្ទដៃពីជនជាប់ចោទវិញ បណ្តាលឱ្យមានស្នាមជាំដើមដៃខាងឆ្វេង ជាំជង្គង់ខាងឆ្វេង និងកែងដៃខាងឆ្វេង ដែលនេះសបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ខេង ពិតជាបានប្រើអំពើហិង្សាទៅលើជនរងគ្រោះឈ្មោះ [redacted] ហ្សរ ប្រាកដមែន។ ឃើញថាមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ខេង ពីបទ ផលិត ចែកចាយរូបភាព និងសម្ភារៈសអាភាសនៃកុមារ ប្រព្រឹត្តនៅខេត្តកំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ២០២២ តាមបញ្ញត្តិនៃមាត្រា ៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅសាលាវិទ្យាល័យចំណោះ ទូទៅ និងបច្ចេកទេស ព្រះបាទសម្តេចនរោត្តមសីហមុនី ស្ថិតក្នុងភូមិសាលាលេខ៥ [redacted] ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិនៃមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។ តំណាងអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ខេង ក្នុងកម្រិតអតិបរមា។

**សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

-លោក [redacted] សាង ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានពីភាក្សាដេញដោលនាពេលសវនាការរួចហើយ ឃើញថា ចំពោះបទល្មើស ផលិតរូបភាព បើពិនិត្យមើលពាក្យផលិត គឺជាការរៀបចំ តាក់តែង ពេលវេលាច្បាស់លាស់ ទើបហៅថាផលិត ជាក់ស្តែងគឺមានការថតរូបរវាងជនជាប់ចោទ និងជនរងគ្រោះ ដែលមានអាយុ១៦ ឆ្នាំ ប្រសិនបើកូនក្តីខ្លួនជាប់ពាក់ព័ន្ធបទល្មើសផលិត ចឹងជនរងគ្រោះចូលរួមផលិតដូចគ្នាដែរ។ បើពិនិត្យមើលជាក់ស្តែងដូចមិនមានការរៀបចំ ឬផលិតជាវីដេអូអ្វីឡើយ គ្រាន់តែជាការថតលេង។ ចំពោះការចែកចាយរូបភាព និងវីដេអូ គឺពុំមានសាក្សីណាបានឃើញមានវីដេអូអាសអាភាស ឬរូបភាពបែកធ្លាយនោះទេ។ សាក្សីឈ្មោះ [redacted] ម៉ាស គ្រាន់តែលឺគេនិយាយ ដោយមិនបានឃើញផ្ទាល់នោះទេ។ ពាក់ព័ន្ធករណីហិង្សា កូនក្តីរបស់ខ្លួនគ្រាន់តែក្រវាសដៃប៉ុណ្ណោះ មិនបានចាប់បោកជនរងគ្រោះនោះទេ ហើយករណីនេះ បានធ្វើការសម្របសម្រួលគ្នា និងបានធ្វើកិច្ចសន្យាចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ រួចរាល់ហើយដែរ។ ខ្លួនសូមបញ្ជាក់ថាជនរងគ្រោះបានលើកឡើងថា ទៅគេងជាមួយគ្នាលើកទី៣ ក៏កូនក្តីរបស់ខ្លួនបានថតវីដេអូទៅឱ្យជនរងគ្រោះ ប៉ុន្តែជនរងគ្រោះបានថ្លែងក្នុងពាក្យបណ្តឹង និងឆ្លើយក្រោយមក ថារួមភេទជាមួយគ្នាលើកដំបូង ពេលទៅដល់ផ្ទះទើបកូនក្តីរបស់ខ្លួនថតផ្ញើឱ្យ ចំណុចនេះមានវិមតិសង្ស័យ។ ហេតុដូចនេះ ខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនស្នើរសុំឱ្យតុលាការមេត្តាសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតបទចោទប្រកាន់។

-លោក [redacted] លី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការរួចហើយ ឃើញថា កូនក្តីរបស់ខ្លួនជាប់ចំនួន ០៣ បទល្មើស។ ចំពោះពាក្យថាផលិត មានការរៀបចំជាក្រុមដើម្បីផលិត ប៉ុន្តែក្នុងអង្គហេតុនេះ មានភស្តុតាងមានជនរងគ្រោះបានចូលរួមក្នុងសកម្មភាពនេះផងដែរ បើគ្មានការចូលរួមពីជនរងគ្រោះនោះទេ មិនអាចមានការផលិតឡើយ។ ទី២ ពាក់ព័ន្ធរឿងហិង្សា កូនក្តីរបស់ខ្លួនបានធ្វើកិច្ចសន្យា និងបានធ្វើការសម្របសម្រួលគ្នា ព្រមទាំងផ្តល់សំណងរួចរាល់ហើយដែរ។ ទី៣ ចែកចាយរូបភាពអាសអាភាសលើកុមារ ថាតើមានភស្តុតាងណាបញ្ជាក់បានឃើញរូបភាព និងវីដេអូឡើយ។ ជន

ជាប់ចោទមិនបានដាក់ពាក្យសុំនៅក្រៅឃុំឡើយ ដើម្បីទុកឱ្យតុលាការស៊ើបអង្កេតហើយកូនក្តីរបស់ខ្លួនបានចូលបង្ហាញខ្លួននៅគ្រប់នីតិវិធីដោយពុំមានចេតនាគេចវេសនោះទេ។ ហេតុដូចនេះ ខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនស្នើសុំឱ្យតុលាការមេត្តាសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចផុតបទចោទប្រកាន់។

-សំណូមពរចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted]ខេង៖ ស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់ និងដោះលែងខ្លួនឱ្យមានសេរីភាពវិញ ដើម្បីឱ្យខ្លួនបានត្រឡប់ទៅផ្ទះមើលថែគ្រួសារ និងបានទៅបម្រើការងារនៅអង្គភាពដើមវិញ។

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ។

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យលើភស្តុតាងនានា។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-តុលាការបានទទួលបណ្តឹងតាមដីកាដំណោះស្រាយលេខ ៣៨៤/២៣ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted]ខេង ភេទប្រុស អាយុ៤០ ឆ្នាំ (កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨២) មកតុលាការដើម្បីជំនុំជម្រះពីបទ: **ផលិត ចែកចាយរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ** ប្រព្រឹត្តនៅខេត្តកំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅសាលាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេចនរោត្តមសីហមុនី ស្ថិតក្នុង[redacted] ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

២-ផ្អែកតាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted]ហួរ និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ខេង មានភាពស៊ីសង្វាក់គ្នាដែលអាចបញ្ជាក់ឱ្យឃើញថា ជនរងគ្រោះ និងជនជាប់ចោទ ពិតជាបានធ្វើសកម្មភាពរួមភេទជាមួយគ្នា ហើយជនជាប់ចោទបានយកទូរស័ព្ទដៃមកថតសកម្មភាពរួមភេទនេះ និងថតរូបភាពអាក្រាតកាយរបស់ជនរងគ្រោះ រួចបានចែកចាយវីដេអូ និងរូបភាពទាំងនេះទៅអ្នកដទៃ ដោយមានសាក្សីឈ្មោះ កើ លីម៉ាស់ បានបញ្ជាក់ថាពេលខ្លួនទៅហូបការគេបានលឺអ្នកអង្គុយតុជិតនិយាយគ្នាថា មានរូបភាពអាក្រាតកាយ និងវីដេអូរួមភេទរវាងជនជាប់ចោទឈ្មោះ [redacted]ខេង ជាមួយនឹងឈ្មោះ [redacted]ហួរ ដែលស៊ីសង្វាក់នឹងវីដេអូ និងរូបភាពដែលមាននៅក្នុងរបាយការណ៍កោសលវិច្ច័យលេខ ២៩/២៣ របក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ របស់ការិយាល័យកោសលវិច្ច័យទូទៅ នៃក្រសួងមហាផ្ទៃ និងភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿង ដែលការណ៍នេះអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted]ខេង ពិតជាបានផលិត និងចែកចាយរូបភាពអាសអាភាសរបស់ជនរងគ្រោះ ប្រាកដមែន។

៣-ផ្អែកតាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted]ហួរ, ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ខេង និងចម្លើយរបស់សាក្សីឈ្មោះ [redacted]សុជា មានភាពស៊ីសង្វាក់គ្នាដែលអាចឱ្យតុលាការជឿថា ជនជាប់ចោទឈ្មោះ

[redacted]ខេង បានចាប់ដើមដៃរបស់ជនរងគ្រោះឈ្មោះ[redacted]ហ្សួរ ជាប់ក្រវាត់បុកទៅនឹងតុ និងកៅអីដែលនៅក្បែរនោះ និងរុញលអុកគូទទៅលើការ៉ូ បណ្តាលឱ្យមានស្នាមជាំដើមដៃខាងឆ្វេង ជាំជង្គង់ខាងឆ្វេង និងកែងដៃខាងឆ្វេង ដូចដែលមានបង្ហាញនៅក្នុងរូបភាពជាភស្តុតាងដែលមាននៅក្នុងសំណុំរឿង។ នេះសបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ[redacted]ខេង ពិតជាបានប្រើអំពើហិង្សាទៅលើជនរងគ្រោះឈ្មោះ[redacted]ហ្សួរ ប្រាកដមែន។

៤-សកម្មភាពរបស់ជនជាប់ចោទ ប្រព្រឹត្តអំពើ យកទូរស័ព្ទដៃមកថតវីដេអូជាសកម្មភាពរួមភេទរវាងខ្លួន និងជនរងគ្រោះ និងថតរូបភាពអាក្រាតកាយរបស់ជនរងគ្រោះ ដែលអំពើនេះត្រូវបានកំណត់ថាជាបទល្មើស **ផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ** ស្របតាមបញ្ញត្តិមាត្រា៤១ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ បន្ថែមលើនេះ បន្ទាប់ពីបានថតវីដេអូ និងរូបភាពទាំងនោះ ជនជាប់ចោទបានចែកចាយវីដេអូ និងរូបភាពទាំងនោះទៅអ្នកដទៃ ដែលអំពើនេះត្រូវបានកំណត់ថាជាបទល្មើស **ចែកចាយរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ** ស្របតាមបញ្ញត្តិមាត្រា៤១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ជនជាប់ចោទបានចាប់ដើមដៃរបស់ជនរងគ្រោះជាប់ ហើយក្រវាត់បុកទៅនឹងតុ និងកៅអីដែលនៅក្បែរនោះ និងរុញលអុកគូទទៅលើការ៉ូ បណ្តាលឱ្យមានស្នាមជាំដើមដៃខាងឆ្វេង ជាំជង្គង់ខាងឆ្វេង និងកែងដៃខាងឆ្វេង ដែលអំពើនេះត្រូវបានកំណត់ថាជាបទ **ហិង្សាដោយចេតនា** ស្របតាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

៥-អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់រូបរាងកាយឯកជនរបស់ជនរងគ្រោះ កិត្តិយស សេចក្តីថ្លៃថ្នូរ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គមដែលត្រូវច្បាប់ហាមឃាត់ និងបានបំពានទៅលើមាត្រា៤១ កថាខណ្ឌទី១ និងកថាខណ្ឌទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

៦-បន្ទាប់ពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោកស្រី[redacted]លី ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី, លោក[redacted]សម័យ ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ, លោក[redacted]សាង និងលោក[redacted]លី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ, និងសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណាតាមច្បាប់។

៧-បន្ទាប់ពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ដែលបានស្នើឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាអំពីការផ្តន្ទាទោសជនជាប់ចោទពីបទរំលោភសេពសន្ថវៈ និងបន្ទាប់ពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងជនរងគ្រោះ ព្រមទាំងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងរួចហើយ ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថាពុំមានធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈនោះទេ។ ដូចនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណាសម្រេចបដិសេធលើការស្នើសុំនេះ។

៨-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]ខេង ភេទប្រុស អាយុ៤០ ឆ្នាំ ជនជាតិខ្មែរ ពីបទ៖ **ផលិត ចែកចាយរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ** ប្រព្រឹត្តនៅខេត្តកំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា៤១ កថាខណ្ឌទី១ និងទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវ

កម្មផ្លូវភេទ និងបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅសាលាវិទ្យាល័យចំណោះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេចនរោត្តមសីហមុនី ស្ថិតក្នុងភូមិ[redacted] ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

៩-ជនជាប់ចោទឈ្មោះ[redacted]ខេង ជានីតិជនមានស្មារតីដឹងខុសត្រូវនូវអំពើ និងព្យសនកម្ម ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ក៏ដូចជាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌស្របទៅតាមច្បាប់។

១០-វត្ថុតាងរួមមាន៖ ទូរស័ព្ទម៉ាក IPHONE 13 PRO MAX ពណ៌ខៀវ លេខ ០១២ ៩០១ ២១១ និងលេខ ០៧១ ៣៣៤ ៩១១២ ដែលលេខ IMEI 353240585440170 លេខ IMEI 353240585250793 ចំនួន ០១ គ្រឿង, ទូរស័ព្ទ NOKIA ពណ៌ខ្មៅលេខ ០៩៦ ៣៣៩ ៩៣៧៧ ចំនួន ០១ គ្រឿង, USB ទំហំ ១៦ GB មានផ្ទុកទិន្នន័យភស្តុតាង និងកុំព្យូទ័រយួរដៃ (Laptop) ម៉ាក ASUS ពណ៌ប្រផេះ ចំនួន ០១ គ្រឿង គឺជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូស តាមបញ្ញត្តិមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ហុង បានប្តឹងទាមទារសំណងជាទឹកប្រាក់ចំនួន ២០០,០០០,០០០ (ពីររយលាន) រៀល។ គប្បីតុលាការលើកយកមកពិចារណា និងសម្រេចអំពីសំណងនេះ ស្របតាមស្ថានភាពជាក់ស្តែងរបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងស្របតាមព្យសនកម្មដែលកើតមានចំពោះជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។

## <u>ហេតុដូច្នេះសម្រេច</u>

**១/-ផ្តន្ទាទោសលើជនជាប់ចោទ:**

- ឈ្មោះ[redacted]ខេង ភេទប្រុស អាយុ៤០ ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

**ដាក់ពន្ធនាគារកំណត់រយៈពេល ០៨ (ប្រាំបី) ឆ្នាំ ពីបទ៖ ផលិត ចែកចាយរូបភាព និងសម្ភារៈអាសអាភាសនៃ**កុមារ ប្រព្រឹត្តនៅខេត្តកំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា៤១ កថាខណ្ឌទី១ និងទី៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅសាលាវិទ្យាល័យចំណោះទូទៅ និងបច្ចេកទេសព្រះបាទសម្តេចនរោត្តមសីហមុនី ស្ថិតក្នុងភូមិ[redacted] ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

**២/-បង្គាប់ឱ្យឈ្មោះ[redacted]ខេង សងសំណងជាទឹកប្រាក់ចំនួន ១០០,០០០,០០០ (មួយរយលាន) រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ហុង។ ការទាមទារលើសពីនេះច្រានចោល។**

**៣/-រឹបអូស វត្ថុតាងរួមមាន៖ ទូរស័ព្ទម៉ាក IPHONE 13 PRO MAX ពណ៌ខៀវ លេខ ០១២ ៩០១ ២១១ និងលេខ ០៧១ ៣៣៤ ៩១១២ ដែលលេខ IMEI 353240585440170 លេខ IMEI 353240585250793 ចំនួន ០១ គ្រឿង, ទូរស័ព្ទ NOKIA ពណ៌ខ្មៅលេខ ០៩៦ ៣៣៩ ៩៣៧៧ ចំនួន ០១ គ្រឿង, USB ទំហំ ១៦ GB មានផ្ទុកទិន្នន័យភស្តុតាង និងកុំព្យូទ័រយួរដៃ (Laptop) ម៉ាក ASUS ពណ៌ប្រផេះ ចំនួន ០១ គ្រឿង។**

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ៧រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កំពង់ឆ្នាំង, ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]